## អេភេសូរ១:៨-១២

ក្នុងពេលនេះ យើងលើកយកកិច្ចការទីពីរដែលព្រះរាជបុត្រារបស់ព្រះ បានបំពេញសម្រាប់ក្រុមជំនុំរបស់ទ្រង់មកពិភាក្សា។ កិច្ចការទីពីរនោះគឺ ព្រះយេស៊ូវគ្រីស្ទបើកសម្តែងអោយយើងស្គាល់សេចក្តីអាថ៌កំបាំងនៃព្រះហឫទ័យរបស់ទ្រង់។

> **៨ ដែលបានផ្តល់មកយើងជាបរិបូរ ដោយនូវប្រាជ្ញា នឹងដំរិះសព្វ
> គ្រប់ ៩ ព្រមទាំងសំដែង ឱ្យយើងរាល់គ្នាស្គាល់សេចក្តីអាថ៌កំបាំង
> នៃព្រះហឫទ័យទ្រង់ តាមគំនិតដែលទ្រង់បានគិតសំរេច ក្នុងព្រះ
> អង្គទ្រង់ ១០ សំរាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញ
> កំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ
> ទាំងរបស់នៅស្ថានសួគ៌ នឹងរបស់នៅផែនដីផង (អេភេសូរ១:៨-
> ១០)។**

នៅក្នុងព្រះគម្ពីរ យើងតែជួបពាក្យអាថ៌កំបាំងជាច្រើនលើកច្រើនសារ។ តើអ្វីទៅដែលហៅថា ជាសេចក្តីអាថ៌កំបាំងក្នុងបទគម្ពីរ? សេចក្តីអាថ៌កំបាំងនៅក្នុងព្រះគម្ពីរ មិនមែនជារឿងដែលយើងមិនអាចយល់បាននោះទេ។ ធម្មតាសេចក្តីអ្វីដែលរាប់ថាជាសេចក្តីអាថ៌កំបាំង មនុស្សមិនអាចដឹងបានទាល់តែសោះ។ ចំណែកនៅក្នុងព្រះគម្ពីរ

សេចក្តីអាថ៌កំបាំង ជាហេតុការណ៍ដែលព្រះបើកសម្តែងអោយមនុស្សលោកយល់ ក្នុងពេលដែលទ្រង់កំណត់។ ចំណុចនេះមានន័យថា កាលពីមុន យើងមិនបានយល់ទេ តែមកទល់ពេលនេះ ព្រះជាម្ចាស់បើកសម្តែងអោយយើងបានយល់។ ដើម្បីអោយយល់អាថ៌កំបាំងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងត្រូវដឹងការពីរយ៉ាង។ ទីមួយ យើងមិនអាចដឹងបានដោយប្រើគំនិតបច្ចុប្បន្នរបស់មនុស្សលោក។ យើងអាចយល់អាថ៌កំបាំងរបស់ព្រះបាន ដោយសារព្រះអង្គទ្រង់បើកសម្តែងអោយយើងយល់។ ឯសេចក្តីទីពីរ គឺព្រះអង្គមិនអោយយើងយល់មុនពេលដែលទ្រង់កំណត់ទុក អាថ៌កំបាំងក្នុងព្រះគម្ពីរ យើងអាចយល់បាន តែត្រូវយល់តាមគំនិតរបស់ព្រះជាម្ចាស់ ក្នុងថេរវេលាដែលទ្រង់កំណត់ទុក។

ទាក់ទងនឹងរឿងអាថ៌កំបាំងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី លោកស្កូហ្វៀលបានរកឃើញអត្ថន័យទាំងអស់ចំនួនដប់មួយប្រភេទ។ ប្រភេទទីមួយ ជាអាថ៌កំបាំងនៃនគរស្ថានសួគ៌ (គម្ពីរម៉ាថាយ១៣:៣-៥០)។ ទីពីរ ជាអាថ៌កំបាំងដែលសាសន៍អ៊ីស្រាអែលមិនអាចយល់បាននៅក្នុងគ្រាបច្ចុប្បន្ន (គម្ពីររ៉ូម១១:២៥)។ ទីបី ជាអាថ៌កំបាំងទាក់ទងនឹងព្រះជាម្ចាស់បំផ្លាស់បំប្រែពួកបរិសុទ្ធរបស់ទ្រង់ នៅគ្រាចុងបំផុតនៃយុគសម័យយើងសព្វថ្ងៃ (គម្ពីរ១កូរិនថូស១៥:៥១-៥២ គម្ពីរ១ថែស្សាឡូនីច៤:១៣-១៧)។ អាថ៌កំបាំងទីបួន គឺក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រិស្តក្នុងគ្រាសញ្ញាថ្មី មានរួមទាំងសាសន៍យូដាទាំងសាសន៍ដទៃ (គម្ពីរអេភេសូរ៣:១-១២ គម្ពីររ៉ូម១៦:២៥ គម្ពីរអេភេសូរ៦:១៩ គម្ពីរកូល៉ុស៤:៣)។ អាថ៌កំបាំងទីប្រាំ គឺក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រិស្ត ជាភរិយាថ្មោងថ្មីរបស់ទ្រង់ (គម្ពីរអេភេសូរ៥:២៣-៣២)។ អាថ៌កំបាំងទីប្រាំមួយ គឺចេស្តា

របស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទសណ្ឋិតនៅក្នុងជីវិតអ្នកជឿព្រះអង្គ (គម្ពីរកាឡាទី២:២០ កូល៉ុស១:២១-២៧)។ អាថ៌កំបាំងទីប្រាំពីរ គឺព្រះគ្រីស្ទបើកសម្តែងអោយយើងស្គាល់ព្រះដ៏ខ្ពស់បំផុតនៃស្ថានសួគ៌ (គម្ពីរ១កូរិនថូស២:៧ កូល៉ុស២:២ និង៩)។ អាថ៌កំបាំងទីប្រាំបី គឺព្រះគ្រីស្ទបំផ្លាស់បំប្រែមនុស្សមានបាប អោយទៅជាអ្នកដែលមានលក្ខណៈសម្បត្តិដូចរូបអង្គទ្រង់ (គម្ពីរ១ធីម៉ូថេ៣:១៦)។ អាថ៌កំបាំងទីប្រាំបួន គឺការអត់ទោសអំពើបាបដល់មនុស្សលោក (គម្ពីរ២ថែស្សាឡូនីច២:៧ គម្ពីរម៉ាថាយ១៣:៣៣)។ អាថ៌កំបាំងទីដប់ ជាអាថ៌កំបាំងនៃផ្កាយទាំងប្រាំពីរ (គម្ពីរវិវរណៈ១:២០)។ រីឯអាថ៌កំបាំងទីដប់មួយ គឺជាអាថ៌កំបាំងនៃទីក្រុងបាប៊ីឡូន (គម្ពីរវិវរណៈ១៧:៥ និង៧)។

ទោះបីយើងអាចរកឃើញអាថ៌កំបាំង ទាំងដប់មួយមុខយ៉ាងដូច្នោះហើយក៏ដោយ យើងត្រូវដឹងថា ព្រះជាម្ចាស់មិនចាំបាច់បើកអោយយើងដឹងអ្វីទាំងអស់នៅក្នុងគំនិតរបស់ទ្រង់ទេ។ ខ្ញុំផ្ទាល់មិនអាចស្គាល់អាថ៌កំបាំងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់អោយអស់សេចក្តីបានដែរ។ រៀងរាល់ខែ ខ្ញុំទទួលសំណួរជាច្រើនពីបងប្អូនអ្នកស្តាប់។ ខ្ញុំខំប្រឹងព្យាយាមឆ្លើយនឹងសំណួរទាំងនោះបានខ្លះ តែសំណួរខ្លះខ្ញុំក៏មិនដឹងខ្លួនឯងដែរ។ យើងត្រូវរងចាំទំរាំដល់ថ្ងៃណាមួយ ព្រះអង្គនឹងបើកសម្តែងអោយយើងយល់ជាមិនខាន។

ខ្ញុំសូមបញ្ជាក់ម្តងទៀត ពីអត្ថន័យនៃពាក្យអាថ៌កំបាំងនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អាថ៌កំបាំងគឺជាហេតុការណ៍ដែលព្រះជាម្ចាស់បើកសម្តែងអោយយើងយល់ដោយគំនិតរបស់ទ្រង់ ក្នុងពេលទ្រង់កំណត់។ នៅក្នុងខដែលយើងត្រូវសិក្សានេះ

មានអាថ៌កំបាំង ដែលនៅក្នុងគ្រាគម្ពីរសញ្ញាចាស់មនុស្សលោកមិនទាន់បានយល់នៅឡើយ។ ៨ចែងថា "ដែលបានផ្តល់មកយើងជាបរិបូរ ដោយនូវប្រាជ្ញា នឹងដំរិះសព្វគ្រប់"។ ពាក់កណ្តាល៨មានសេចក្តីដែលចែងថា "ដោយនូវប្រាជ្ញា នឹងដំរិះសព្វគ្រប់"។ សេចក្តីនេះត្រូវស្ថិតនៅក្នុង៩ ទើបត្រឹមត្រូវ។ ៩ត្រូវអានថា "ដោយនូវប្រាជ្ញា នឹងដំរិះសព្វគ្រប់ ទ្រង់បើកសម្តែងឱ្យយើងរាល់គ្នាស្គាល់សេចក្តីអាថ៌កំបាំងនៃព្រះហឫទ័យទ្រង់..."។ តើអ្វីទៅ ដែលជាសេចក្តីអាថ៌កំបាំងនៃព្រះហឫទ័យទ្រង់? អាថ៌កំបាំងនៃព្រះហឫទ័យទ្រង់ អាចយល់ដឹងបានដោយងាយផង អាចយល់ដឹងដោយលំបាកផង។ អាថ៌កំបាំងដែលងាយយល់ គឺដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទផ្តល់មកដើម្បីអោយមនុស្សលោកបានរួចពីអំពើបាប។ យើងត្រូវការដំណឹងល្អ ដែលមានលក្ខណៈងាយយល់ ដើម្បីអធិប្បាយអោយមនុស្សលោកមានបាបស្តាប់។ បើគេពិបាកយល់ គេមិនអាចទទួលជឿព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះបានដែរ។ បណ្ឌិតអាយរ៉ុន-សាយដ៍មានប្រសាសន៍ថា "បើចង់អោយនំក្មេងទទួលទាន ត្រូវដាក់នំទាបល្មមអោយវាឈោងដល់"។ មែនហើយ ដំណឹងល្អត្រូវធ្វើអោយមានលក្ខណៈងាយយល់ ទើបគេទទួលបាន។ ការយល់ដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺជាបំណងព្រះហឫទ័យរបស់ព្រះអង្គ។ ប៉ុន្តែ អាថ៌កំបាំងនៃព្រះហឫទ័យខ្លះទៀតរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងមិនអាចយល់ដោយងាយៗទេ។ យើងចាំបាច់ត្រូវធ្វើការខិតខំប្រឹងប្រែង អោយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះអង្គ ទើបយើងយល់ពីផែនការរបស់ទ្រង់។ ព្រះជាម្ចាស់ចង់អោយយើងយល់ពីអាថ៌កំបាំងទាំងនោះ ពីព្រោះព្រះអង្គបើកសម្តែងអាថ៌

កំបាំងនោះរួចជាស្រេចហើយ។

"សំរាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញកំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ"។ ឥឡូវនេះ យើងឃើញពាក្យ "ពេលពេញកំណត់បានមកដល់"។ ពេលពេញកំណត់ គឺជាពាក្យគន្លឹះមួយទៀត ដែលមានអត្ថន័យស្មើនឹងពាក្យអាថ៌កំបាំងដែរ។ ពាក្យ "ពេលពេញកំណត់" មានការយល់ច្រឡំច្រើនណាស់។ ដោយសារមានការយល់ច្រឡំ មានគ្រូអធិប្បាយព្រះបន្ទូលខ្លះមិនយកពាក្យនោះមកប្រើសោះតែម្តង។ នៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ មានពាក្យជាច្រើនដែលគេមិនចូលចិត្តប្រើ ដូចជាពាក្យព្រះលោហិត សេចក្តីប្រោសលោះ និងឈើឆ្កាងជាដើម។ សាវ៉កប៉ុលមានប្រសាសន៍ថា ឈើឆ្កាងជាទីបង្អាក់បង្អន់ចិត្តដល់មនុស្សលោក បានជាលោកមិនអាចឈប់និយាយពីឈើឆ្កាងបាន។ ព្រះគម្ពីរមានសម្តែងពីពាក្យ "ពេលពេញកំណត់"។ ដូច្នេះ យើងមិនអាចចៀសវាងនិយាយប្រធានបទនេះបានទាល់តែសោះ។

តើពាក្យ "ពេលពេញកំណត់" មានន័យយ៉ាងដូចម្តេច? ពេលពេញកំណត់មិនអាចប្រើដោយយកថេរវេលាមកកំណត់ទេ។ ពេលពេញកំណត់ខុសពីយុគកំណត់។ នៅក្នុងការសិក្សាព្រះគម្ពីរ យើងធ្លាប់ឮគេនិយាយពីគ្រាព្រះគុណ។ កាលណាយើងនិយាយគ្រាព្រះគុណ យើងនិយាយពីពេលវេលាដែលព្រះជាម្ចាស់ផ្តល់ព្រះគុណមកគ្របដណ្តប់លើមនុស្សមានបាប។ ពេលពេញកំណត់មានអត្ថន័យផ្សេងពីគ្រាកំណត់។ "ពេលពេញកំណត់" អាចមានន័យថា ជាសេវាកម្ម ជាសណ្តាប់ធ្នាប់ ឬជារដ្ឋបាល។ នៅក្នុងភាសា

ក្រែកពាក្យថា ពេលពេញកំណត់ អាចបកប្រែអោយចំថា ឋានានុក្រម មានន័យថា កិច្ចការដែលត្រូវធ្វើតាមឋានៈ តាមលំដាប់លំដោយ តាមវគ្គ តាមស្មើ។

ដើម្បីអោយយល់ពាក្យ "ពេលពេញកំណត់" ខាងលើ ខ្ញុំសូមជូនឧទាហរណ៍ខ្លះៗ ដូចខាងក្រោម។ នៅតាមសាលារៀននៃប្រទេសដែលមានការចម្រើនល្អតលាស់ សិស្សសាលាគ្រប់រូប ត្រូវជ្រើសរើសមុខវិជ្ជាតាមចំណង់ចំណូលចិត្តរបស់ខ្លួន។ ខ្លះជ្រើសរើសយកមុខវិជ្ជាសេដ្ឋកិច្ច ដូចជាសេដ្ឋកិច្ចមូលដ្ឋានជាដើម។ សេដ្ឋកិច្ចមូលដ្ឋានមានរួមទាំងរបៀបចាត់ចែងកិច្ចការងារក្នុងផ្ទះ រហូតដល់របៀបរកស៊ីជួញដូររវាងគ្រួសារ និងគ្រួសារ រវាងភូមិមួយទៅភូមិមួយ ពីស្រុកមួយទៅស្រុកមួយ និងពីខេត្តមួយទៅខេត្តមួយជាដើម។ ឯរបៀបចាត់ចែងសេដ្ឋកិច្ចក្នុងគ្រួសារ យើងអាចប្រៀបឧបមាដូចជាស្ត្រីមេផ្ទះមួយរូប។ មេផ្ទះរូបនោះ គិតទុកជាស្រេចក្នុងសប្តាហ៍នេះថា តើថ្ងៃនេះ គាត់ធ្វើម្ហូបអ្វីនៅពេលព្រឹក គាត់ធ្វើម្ហូបអ្វីនៅពេលល្ងាច។ ឧទាហរណ៍ថា ស្ត្រីមេផ្ទះម្នាក់បម្រុងធ្វើសម្លកកូរនៅពេលថ្ងៃត្រង់។ ពេលល្ងាចគាត់អាំងត្រីងៀតទទួលទានជាមួយឪឡឹក។ ឯស្ត្រីមេផ្ទះម្នាក់ទៀតនៅក្បែរផ្ទះគាត់ ជ្រើសរើសអាំងត្រីងៀតទទួលទានជាមួយឪឡឹកនៅពេលព្រឹក ល្ងាចឡើងគាត់ស្លម្ជូរគ្រឿងសាច់រឿង។ ការរៀបរយគំនិតដូចជម្រាបជូនខាងលើ ជាសេចក្តីដែលក្នុងព្រះគម្ពីរនិយាយថា "ពេលពេញកំណត់"។ "ពេញពេញកំណត់" ខាងលើ ជារបៀបរៀបចំសេដ្ឋកិច្ចមូលដ្ឋាន។

ទាក់ទងនឹងកិច្ចការសេដ្ឋកិច្ច សិស្សសាលាខ្លះជ្រើសរើសយកសេដ្ឋកិច្ចនយោបាយ។ សិស្សដែលរើសយកមុខវិជ្ជានេះ ច្រើនជាអ្នកដែលមានបំណងចង់ធ្វើជារាជការ

ឬកិច្ចការរដ្ឋ។ នៅក្នុងប្រទេសនីមួយៗមានរបបរដ្ឋាភិបាលខុសៗគ្នា។ ប្រទេសកម្ពុជាមានរបបរដ្ឋាភិបាលម្យ៉ាង ឯប្រទេសថៃមានរបៀបគ្រប់គ្រងម្យ៉ាងផ្សេងទៀត។ ប្រទេសវៀតណាមមានរបៀបដឹកនាំរបស់គេម្យ៉ាងផ្សេងទៀតដែរ។ នៅលើលោកនេះ នគរនីមួយៗពិបាកនឹងរករបៀបដឹកនាំនយោបាយដូចគ្នាទាំងស្រុងណាស់។ នៅប្រទេសខ្មែរ គេធ្វើចរាចរណ៍ដោយប្រកាន់ស្តាំជានិច្ច។ នៅប្រទេសថៃ គេធ្វើដំណើរប្រកាន់ឆ្វេង។ ស្តាំរបស់ខ្មែរ ជាឆ្វេងរបស់ថៃ។ របៀបដឹកនាំរបស់នគរនីមួយៗមានលក្ខណៈខុសគ្នា។ ការកំណត់អោយមានរបៀបរបបខុសគ្នានេះហើយ ក្នុងគម្ពីរហៅថា "ពេលពេញកំណត់"។

"ពេលពេញកំណត់" អាចប្រើត្រូវខ្លះៗសម្រាប់ការកំណត់ថេរវេលាដែរ។ នៅក្នុងថេរវេលាណាមួយ ព្រះជាម្ចាស់ត្រូវសម្រេចធ្វើអ្វីមួយ តាមវិធីណាមួយ ដែលទ្រង់គិតសម្រេចនឹងធ្វើ។ ឧទាហរណ៍ ព្រះជាម្ចាស់រៀបចំជីវិតសម្រាប់លោកតាអ័ដាមរស់នៅខុសពីជីវិតរស់នៅដែលយើងត្រូវប្រកាន់យកក្នុងពេលសព្វថ្ងៃ។ ពីសម័យឆ្នាំ៦០ ទីក្រុងភ្នំពេញរាប់ថា ជាស្ថានសួគ៌ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ខ្ញុំផ្ទាល់បានទៅលេងទីក្រុងភ្នំពេញនៅក្នុងឆ្នាំនេះឃើញថាមានសម្ផស្សល្អមែន។ សព្វថ្ងៃនេះវិញ ទីក្រុងភ្នំពេញមិនអាចចាត់ទុកថា ជាស្ថានសួគ៌នៅអាស៊ីអាគ្នេយ៍បានទៀតទេ។ គ្រាមួយ មានលក្ខណៈខុសពីគ្រាមួយទៀត។ ក្នុងគម្ពីរចំណុចនេះហៅថា "ពេលពេញកំណត់" ដែរ។

ប៉ុន្តែ បើនិយាយពីរបៀបដែលព្រះជាម្ចាស់ផ្តល់សេចក្តីសង្គ្រោះមកដល់មនុស្សមានបាបវិញ ព្រះអង្គមិនដែលប្តូរផ្លាស់ទេ ទោះជា "ពេលពេញកំណត់" នោះ

របៀបជាឋានានុក្រម ឬ "ពេលពេញកំណត់" ជាថេរវេលា។ ព្រះអង្គផ្តល់សេចក្តីសង្គ្រោះមកដល់មនុស្សលោកតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដោយទ្រង់ត្រូវសុគតនៅលើឈើឆ្កាង ហើយរស់ពីឡើងវិញ។ ប៉ុន្តែ របៀបដែលត្រូវចូលទៅដើម្បីទទួលសេចក្តីសង្គ្រោះ អាចមានលក្ខណៈខុសគ្នាតាម "ពេលពេញកំណត់" ដូចព្រះជាម្ចាស់បានគិតសម្រេចក្នុងគំនិតរបស់ទ្រង់។ ឧទាហរណ៍ក្នុងករណីលោកអេបិល និងលោកអ័ប្រាហាំ ចូលមកទទួលសេចក្តីសង្គ្រោះដោយយកកូនចៀមមកថ្វាយដល់ព្រះជាម្ចាស់ជាយញ្ញបូជា។ កូនចៀមនៃព្រះគឺអង្គព្រះយេស៊ូវគ្រីស្ទ។ ព្រះជាម្ចាស់អនុញ្ញាតអោយពួកបរិសុទ្ធក្នុងគ្រាគម្ពីរសញ្ញាចាស់ធ្វើយញ្ញបូជា ពីព្រោះព្រះអង្គគិតសម្រេចថា ផ្លូវនោះជាផ្លូវត្រឹមត្រូវ។ ឯផ្លូវត្រឹមត្រូវនោះទៀតសោត គឺពួកបរិសុទ្ធក្នុងព្រះគម្ពីរសញ្ញាចាស់ជឿលើព្រះបន្ទូលដែលទ្រង់សន្យា។ ក្នុងពេលបច្ចុប្បន្ននេះវិញ ខ្ញុំសង្ឃឹមថា លោកអ្នកមិនចាំបាច់ដឹកកូនចៀមទៅថ្វាយតង្វាយនៅថ្ងៃអាទិត្យទេ។ យើងមិនចាំបាច់ចូលទៅព្រះអង្គតាមរយៈការថ្វាយតង្វាយកូនចៀមទៀត ពីព្រោះព្រះជាម្ចាស់ប្រើវិធីផ្សេង ដើម្បីអោយយើងចូលទៅជិតព្រះអង្គក្នុងពេលបច្ចុប្បន្ន។ សេចក្តីទាំងអម្បាលមាណដែលសម្តែងខាងលើ ជា "ពេលពេញកំណត់"។

ក្នុងកាលដែលពេលពេញកំណត់បានមកដល់"។ តើ "ពេលពេញកំណត់ "បានមកដល់ជាអ្វី? ពេលពេញកំណត់មកដល់ គឺជាពេលដែលព្រះជាម្ចាស់ទ្រង់សម្រេចអោយ អ្វីៗទាំងអស់ស្ថិតនៅក្រោមការកាន់កាប់ត្រួតត្រារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ លុះពេលពេញកំណត់បានមកដល់ អ្វីៗទាំងអស់ដែលកើតមានឡើងក្នុងគ្រាអតីតៈ អ្វីៗ

ទាំងអស់ដែលកើតមានឡើងក្នុងគ្រាបច្ចុប្បន្ន នឹងអ្វីៗទាំងអស់ដែលកើតមានឡើងក្នុងគ្រាអនាគត ត្រូវបំព្រួមអោយមកស្ថិតនៅក្រោមការកាន់កាប់ត្រួតត្រារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ត្រង់នេះមានន័យថា មាបនភារៈទាំងឡាយទាំងពួងត្រូវធ្វើការមួយដល់ពេលពេញកំណត់បានមកដល់។ ឯការដែលគេត្រូវធ្វើគឺ គ្រប់ជង្គង់ត្រូវលុតចុះ ហើយគ្រប់ទាំងអណ្តាតត្រូវសារភាពថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទពិតជាព្រះដ៏ដួចដំណឹងល្អបានប្រកាសមែន។ សេចក្តីនេះហើយ ជាអាថ៌កំបាំងដែលព្រះជាម្ចាស់បើកអោយយើងស្គាល់ព្រះហឫទ័យទ្រង់ក្នុងព្រះគ្រីស្ទយេស៊ូវ។ ឯអាថ៌កំបាំងនោះទៀតសោតគឺ ដល់ពេលពេញកំណត់ ព្រះជាម្ចាស់បំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ ទាំងរបស់នៅស្ថានសួគ៌ និងរបស់នៅផែនដីផង អោយស្ថិតនៅក្រោមការកាន់កាប់ត្រួតត្រារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជាម្ចាស់។ គម្ពីរហេព្រើរ២:៨បញ្ជាក់បន្ថែមទៀតថា "ទ្រង់បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នៅក្រោមជើងគេ" ហើយដែលទ្រង់បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នោះគឺមិនបានទុកអ្វី ដែលមិនចុះចូលសោះឡើយ តែសព្វថ្ងៃនេះ យើងមិនទាន់ឃើញគ្រប់ទាំងអស់ចុះចូលនៅឡើយទេ"។ បច្ចុប្បន្ននេះ យើងមិនទាន់ឃើញសេចក្តីគ្រប់បែបយ៉ាង ត្រូវស្ថិតនៅក្រោមការកាន់កាប់ត្រួតត្រារបស់ព្រះគ្រីស្ទទាំងស្រុងនៅឡើយ។ ដូច្នេះបច្ចុប្បន្ន យើងស្ថិតនៅក្រោមពេលពេញកំណត់ ដោយឡែកខុសពីពេលពេញកំណត់ដែលត្រូវកើតឡើងក្នុងគ្រាអនាគត។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់បានបើកសម្តែងអោយយើងស្គាល់អាថ៌កំបាំង ដែលកាលពីគ្រាអតីតៈមិនទាន់បានបើកសម្តែងអោយនរណាស្គាល់នៅឡើយ។

បច្ចុប្បន្ននេះ ស្ថានសួគ៌និងផែនដីលេងភ្លេងមិនទាន់ត្រូវសម្លេងគ្នានៅឡើយ។ នៅផែនដី គេលេងភ្លេងផ្សេង នៅស្ថានសួគ៌ គេលេងភ្លេងផ្សេងទៀត។ នៅផែនដីគេប្រើភ្លេងដើម្បីនាំមនុស្សអោយឆ្ងាយពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ តាមពិតឧបករណ៍ភ្លេងនិងចម្រៀងគ្រប់បែបយ៉ាង ត្រូវលេងសម្រាប់សរសើរដល់ព្រះនាមព្រះអម្ចាស់យេស៊ូវ។ នៅស្ថានសួគ៌ ឧបករណ៍ភ្លេងនិងចម្រៀងគ្រប់បែបយ៉ាង សុទ្ធតែច្រៀងសរសើរតម្កើងដល់ព្រះនាមព្រះជាម្ចាស់។ ភ្លេងនៅស្ថានសួគ៌ និងភ្លេងនៅផែនដីមិនទាន់លេងស៊ីសង្វាក់គ្នាឡើយ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ នឹងមានគ្រាមកដល់ដែលស្ថានសួគ៌ហើយនិងផែនដីលេងភ្លេងតែមួយ គឺភ្លេងទាំងអស់ស្ថិតនៅក្រោមការកាន់កាប់ត្រួតត្រារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ឥឡូវនេះ យើងឈានមកដល់ចំណុចទីបី ដែលនិយាយពីកិច្ចការរបស់ព្រះរាជបុត្រាទ្រង់ ដែលទ្រង់បានបំពេញសម្រាប់ក្រុមជំនុំរបស់ទ្រង់។ ឯកិច្ចការទីបីនោះ គឺព្រះគ្រីស្ទទ្រង់ប្រទានអោយយើងមានកេរមរតកជាមួយទ្រង់។

**១១ឱ្យរួមគ្នាមកក្នុងទ្រង់ ដែលយើងរាល់គ្នាបានកេរ្តិ៍អាករក្នុងទ្រង់**
**ដែរ ដោយទ្រង់បានដំរូវយើងទុកជាមុន តាមដំរិះសំរេចរបស់ព្រះ**
**ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់**
**១២ប្រយោជន៍ឱ្យយើងខ្ញុំ ដែលបានទុកចិត្តជឿដល់ព្រះគ្រីស្ទជាមុន**
**បានសំរាប់នឹងសរសើរដល់សិរីល្អទ្រង់ (អេភេសូរ១:១១-១២)។**

សេចក្ដីដែលចែងក្នុងខខាងលើ ជាសេចក្ដីពិតយ៉ាងត្រចះត្រចង់មួយទៀតសម្រាប់យើង។ ព្រះគ្រីស្ទទ្រង់ប្រទានកេរអាករដល់យើង។ យើងជាមនុស្សលោក មិនមានជាប់សាច់សាលោហិតអ្វី ដើម្បីអោយយើងអាចទទួលកេរមរតកជាមួយនឹងអង្គព្រះយេស៊ូវទេ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់មានផែនការអាចអោយយើងបានទទួលកេរមរតកទាំងឡាយ ដែលព្រះអម្ចាស់យេស៊ូវបានទទួលពីព្រះអង្គដែរ។ យើងជាមនុស្សមានបាបមានសិទ្ធិទទួលកេរមរតក ពីព្រោះព្រះគ្រីស្ទទ្រង់រស់នៅក្នុងខ្លួនយើង។ ព្រះគ្រីស្ទអាចរស់នៅក្នុងខ្លួនយើងបាន ដោយសារយើងជឿដល់ព្រះអង្គថាទ្រង់ជាអង្គសង្គ្រោះ។ ទាក់ទងនឹងរឿងខាងលើ សាវ័កប៉ុលបញ្ជាក់ថា "បើសិនណាជាកូនព្រះហើយ នោះយើងក៏បានគ្រងមរដកដែរ គឺជាអ្នកគ្រងមរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង ឱ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ ដើម្បីឱ្យបានដំកើងឡើងជាមួយនឹងទ្រង់ដែរ" (រ៉ូម៨:១៧)។ ចំណែកគម្ពីរ១កូរិនថូស៣:២១-២៣ សាវ័កប៉ុលបន្ថែមទៀតថា "ដូច្នេះ កុំឱ្យអ្នកណាអួតពីមនុស្សឡើយ ដ្បិតគ្រប់ទាំងអស់ជារបស់ផងអ្នករាល់គ្នា ទោះទាំងប៉ុល ឬអ័ប៉ុឡូស កេផាសលោកីយ ជីវិត សេចក្ដីស្លាប់ របស់នៅជំនាន់សព្វថ្ងៃ ឬទៅមុខក្ដី នោះសុទ្ធតែជារបស់ផងអ្នករាល់គ្នាទាំងអស់ តែឯអ្នករាល់គ្នាជារបស់ផងព្រះគ្រីស្ទវិញ ហើយព្រះគ្រីស្ទ ទ្រង់ជារបស់ព្រះ"។ ខ្ញុំផ្ទាល់ពិបាកយល់ដល់ជម្រៅនៃអាថ៌កំបាំងនេះខ្លាំងណាស់។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ខ្ញុំជឿលើព្រះបន្ទូលសន្យា បានជាខ្ញុំមានសង្ឃឹមថា ថ្ងៃដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទ យាងមកដើម្បីលើកពួកជំនុំទៅជួបជុំជាមួយព្រះអង្គលើអាកាស ខ្ញុំមានឯកសិទ្ធិចូលរួមព្យុហយាត្រាដ៏

មហោឡារិកនោះដែរ។ ពេលនោះអ្វីៗទាំងអស់ជាកម្មសិទ្ធិរបស់ខ្ញុំ។ ព្រះគ្រីស្ទជាកម្មសិទ្ធិរបស់ខ្ញុំ។ សាវ័កប៉ុលជាកម្មសិទ្ធិរបស់ខ្ញុំ។ លើសពីនោះទៅទៀត សូម្បីសេចក្តីស្លាប់ក៏ជាកម្មសិទ្ធិរបស់ខ្ញុំដែរ។ អ្វីៗទាំងអស់ជាកម្មសិទ្ធិរបស់ខ្ញុំ។ ហេតុអ្វីបានជាខ្ញុំមានឯកសិទ្ធិទទួលកេរមរតកដែលព្រះអម្ចាស់យេស៊ូវបានទទួលដែរ? ពីព្រោះព្រះអង្គប្រទានអោយដល់ខ្ញុំ។ ព្រះគ្រីស្ទជារបស់ខ្ញុំ។ ព្រះជាម្ចាស់នៃស្ថានសួគ៌ជារបស់ខ្ញុំ។ តើមានបទពិសោធន៍ណាមួយដែលមានលក្ខណៈថ្លៃថ្លា ខ្ពង់ខ្ពស់ជាងបទពិសោធន៍ដែលដឹងថាយើងជាគ្រីស្ទបរិស័ទអាចទទួលកេរមរតករួមនឹងព្រះអម្ចាស់យេស៊ូវដែរឬទេ?

ខ្ញុំផ្ទាល់ចង់តែស្រែកអោយពេញបំពង់កថា ព្រះជាម្ចាស់ជាព្រះនៃខ្ញុំ ទ្រង់មានសេចក្តីសប្បុរសយ៉ាងអស្ចារ្យ។ ព្រះជាម្ចាស់តម្រូវយើងរាល់គ្នាទុកជាមុន ដើម្បីអោយមានឯកសិទ្ធិបែបនេះ។ សេចក្តីដែលទ្រង់តម្រូវយើងទុកជាមុន គឺនិយាយសម្រាប់តែពួកអ្នកបានទទួលសេចក្តីសង្គ្រោះតែប៉ុណ្ណោះទេ។ សូមចាំអោយច្បាស់ថា ព្រះជាម្ចាស់មិនដែលដៅទុកអោយបុគ្គលណាម្នាក់បាត់បង់ ព្រាត់ប្រាសចេញពីព្រះអង្គឡើយ។ ព្រះអង្គតម្រូវយើងរាល់គ្នាទុកជាមុន ដើម្បីអោយទទួលកេរមរតកជាមួយនឹងអង្គព្រះយេស៊ូវ។ បើព្រះអង្គមិនតម្រូវខ្ញុំទុកជាមុនទេ ខ្ញុំគ្មានលទ្ធភាពអាចទទួលកេរមរតក សូម្បីអ្វីបន្តិចបន្តួចក៏គ្មានដែរ។ ខ្ញុំមិនសមនឹងទទួលកេរមរតកជាមួយព្រះអម្ចាស់យេស៊ូវទាល់តែសោះ។ គ្មានគុណស្រ័យណាដែលខ្ញុំសមនឹងទទួលកេរមតកទាំងនោះទេ។ ព្រះជាម្ចាស់មានបំណងព្រះហឫទ័យអោយពួកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទទួលកេរមរតកជាមួយនឹងអង្គព្រះគ្រីស្ទ។ ព្រះអង្គសម្រេចធ្វើការនោះ សម្រាប់ជាសេចក្តីល្អដល់មនុស្ស

លោកគ្រប់រូប ដែលព្រមជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាអង្គសង្គ្រោះ។

ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានបំពេញកិច្ចការគ្រប់បែបយ៉ាងសម្រាប់យើង គឺទីមួយ ព្រះអង្គលោះយើងដោយប្រើព្រះលោហិតទ្រង់ជាប្រាក់លោះ។ ទីពីរ ព្រះអង្គបើកសម្តែងអោយយើងស្គាល់អាថ៌កំបាំងនៃព្រះហឫទ័យទ្រង់។ រីឯកិច្ចការទីបីដែលព្រះគ្រីស្ទទ្រង់បានបំពេញសម្រាប់ក្រុមជំនុំរបស់ព្រះអង្គ គឺព្រះអង្គប្រទានអោយយើងបានទទួលកេរអាករជាមួយនឹងទ្រង់ដែរ។ ព្រះអង្គធ្វើការទាំងអស់នេះ ដើម្បីក្រុមជំនុំរបស់ទ្រង់។

១១២ ជាបទចម្រៀងមួយទៀត មានលក្ខណៈដូចបទចម្រៀងដែលសាវ័កប៉ុលសរសេររួចមកហើយ។ បទបន្ទរនេះ បានសរសេរម្តងស្រដៀងនៅក្នុង៦ដែរ។ ខនោះសម្តែងថា "ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់"។ ឃ្លានោះ សាវ័កប៉ុលសរសេរបន្ទាប់ពីលោកពន្យល់ពីកិច្ចការរបស់ព្រះវរបិតា ដែលទ្រង់បានបំពេញសម្រាប់ក្រុមជំនុំរបស់ទ្រង់។ ឥឡូវនេះ បន្ទាប់ពីលោកបានពន្យល់ពីកិច្ចការរបស់ព្រះរាជបុត្រាធ្វើសម្រាប់ក្រុមជំនុំរបស់ទ្រង់ លោកសរសេរបទបន្ទរនេះម្តងទៀតថា "ប្រយោជន៍ឱ្យយើងខ្ញុំដែលបានទុកចិត្តជឿដល់ព្រះគ្រីស្ទជាមុន បានសំរាប់នឹងសរសើរដល់សិរីល្អទ្រង់"។ បុព្វហេតុចម្បងបង្អស់ដែលគ្រីស្ទបរិស័ទត្រូវរស់នៅក្នុងលោកនេះ គឺត្រូវរស់នៅសម្រាប់នឹងសរសើរដល់សិរីល្អនៃព្រះដ៏ខ្ពស់បំផុត។ ព្រះអង្គគង់នៅ មិនមែនសម្រាប់ធ្វើការបំពេញចិត្តដល់គ្រីស្ទបរិស័ទទេ។ គ្រីស្ទបរិស័ទវិញទេតើ ដែលត្រូវរស់នៅសម្រាប់សរសើរសិរីល្អដល់ព្រះអង្គវិញ។ ពេលណាគ្រីស្ទបរិស័ទរស់នៅក្នុងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទោះជាជីវិតនោះរស់នៅបែបណាក្តី ជីវិតរបស់គ្រីស្ទបរិស័ទ មានន័យ

ខ្លឹមសារយ៉ាងជាក់លាក់។ ឯអត្ថន័យនៃជីវិតរបស់គ្រីស្ទបរិស័ទ ដែលរស់នៅក្នុងបំណងព្រះហឫទ័យព្រះជាម្ចាស់ គឺសម្រាប់នឹងសរសើរដល់សិរីល្អទ្រង់។ បើគ្រីស្ទបរិស័ទរស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គ្រីស្ទបរិស័ទយល់ថា ជីវិតរស់នៅរបស់ខ្លួនគ្មានន័យទេ។ ដូច្នេះ ទោះបីយើងរស់នៅមានស្ថានភាពបែបណាក្តី បើយើងដឹងថាការរស់នៅបែបនោះជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ការនោះធ្វើអោយជីវិតយើងមានលក្ខណៈថ្លៃថ្នូរ ប្រកបដោយអត្ថន័យ អំណរ និងជាសេរីល្អរបស់ព្រះជាម្ចាស់។ សូមចាំអោយច្បាស់ថា មូលហេតុដែលយើងរស់នៅសព្វថ្ងៃនេះ គឺយើងស់នៅសម្រាប់នឹងថ្វាយសរសើរដល់សិរីល្អនៃទ្រង់។ ការសរសើរដល់សិរីល្អនៃទ្រង់ជាវត្ថុបំណងចម្បងបង្អស់សម្រាប់គ្រីស្ទបរិស័ទគ្រប់រូប ទោះជាជីវិតគ្រីស្ទបរិស័ទរស់នៅក្នុងស្ថានភាពបែបណាក្តី។

យើងស្លេះការសិក្សាគម្ពីរអេភេសូរត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"